ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៤៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតនាយកដ្ឋានចារកម្ម នៃក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតនាយកដ្ឋានចារកម្ម ចំណុះនាយកដ្ឋានកណ្តាលសន្តិសុខ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ សំរាប់បំពេញភារកិច្ចប្រមូលពត៌មានក្រៅប្រទេស សំដៅបំរើអោយការងារការពារសន្តិសុខជាតិ ។

**មាត្រា២ .-**

នាយកដ្ឋានចារកម្មមានភារកិច្ច ដូចខាងក្រោម :

- ផ្តើមស្នើចាត់តាំង មន្ត្រីប្រតិបត្តិការនៅអមស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ដោយមិនបំពេញការងារជាអគ្គកុងស៊ុល ឬផ្តើមស្នើចាត់តាំង មន្ត្រីជាតំណាងអង្គការ សមាគមផ្សេងៗ ដើម្បីបំពេញការងារចារកម្មក្រៅប្រទេស ។
- ប្រមូលពត៌មានពាក់ព័ន្ធដល់ការប៉ះពាល់អធិបតេយ្យភាព សន្តិសុខ សេដ្ឋកិច្ច នយោបាយ សន្តិសុខសង្គម របស់ព្រះរាជាណាចក្រកម្ពុជា និងផ្តើមស្នើរាល់គោលការណ៍ និងវិធានការផ្សេងៗជូនថ្នាក់ដឹកនាំពិនិត្យសំរេច ។
- សហការការពារសុវត្ថិភាពជូនពលរដ្ឋកម្ពុជាមាន និស្សិត កម្មករ ពលករ ពាណិជ្ជករ ទេសចរណ៍ គណប្រតិភូ និងមន្ត្រីទូតកម្ពុជា ដែលធ្វើដំណើរ ស្នាក់នៅ បំពេញភារកិច្ចនៅក្រៅប្រទេស តាមរយៈនេះចលនាគេចូលរួមចំណែកការពារសន្តិសុខជាតិ ។
- ក្តាប់បានអំពីផែនការសង្គ្រាមចិត្តសាស្ត្រនានានៅក្រៅប្រទេស ដែលជះឥទ្ធិពលដល់នយោបាយ សេដ្ឋកិច្ចសង្គម និងសន្តិសុខជាតិ ។

- ជាជំហាន១ ផ្តើមស្នើពង្រីកការងារចារកម្មបច្ចេកវិទ្យា បំរើការងារការពារប្រទេស ការពារសន្តិសុខជាតិ និងអន្តរជាតិ ។
- សហការជាមួយបណ្តាស្ថាប័នចារកម្មបរទេសនានា ដើម្បីផ្លាស់ប្តូរពត៌មាន ឬសហប្រតិបត្តិការ ទប់ស្កាត់អំពើភេរវកម្មអន្តរជាតិ និងបទល្មើសនានាដែលប៉ះពាល់ដល់ខឿនសន្តិសុខជាតិ ដោយឈរលើផលប្រយោជន៍ ស្របច្បាប់នៃប្រទេសនីមួយៗ ។
- សហការជាមួយអង្គភាពជំនាញ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ និងបណ្តាក្រសួង ស្ថាប័ន ដើម្បីចាត់បញ្ជូលមន្ត្រីទៅក្នុងក្រសួង ស្ថាប័នទាំងនោះសំដៅបំពេញការងារចារកម្មក្រៅប្រទេស ។
- សហការជិតស្និទ្ធជាមួយសមត្ថកិច្ចជំនាញនានារបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីស៊ើបបញ្ជាក់រកអោយឃើញមុខសញ្ញាចារកម្មដែលបំរើអោយបរទេស ។
- គ្រប់ពត៌មានចារកម្មប្រមូលបានត្រូវវិភាគ វិនិច្ឆ័យ អោយបានគ្រប់ជ្រុងជ្រោយ រួចរាយការណ៍ជូនថ្នាក់ដឹកនាំពិនិត្យសំរេច ។
- លើកគំរោងសំភារៈ ឧបករណ៍បច្ចេកទេស បំរើកិច្ចប្រតិបត្តិការចារកម្ម ដាក់ស្នើជូនថ្នាក់ដឹកនាំពិនិត្យសំរេច ។
- ធ្វើផែនការបណ្តុះបណ្តាលរយៈពេលខ្លី វែង ដើម្បីកសាងធនធានមនុស្ស ទាំងជំនាញ ទាំងភាសាបរទេស និងបច្ចេកទេសវិទ្យាសាស្ត្រទូទៅដល់មន្ត្រីក្រោមឱវាទ ។
- ធ្វើការងាររដ្ឋបាល បុគ្គលិក គណនេយ្យ ភស្តុភាររបស់នាយកដ្ឋាន តាមការកំណត់
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃប្រគល់អោយ ។

**មាត្រា៣ ._**

នាយកដ្ឋានចារកម្ម ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយ ។

**មាត្រា៤ ._**

នាយកដ្ឋានចារកម្មមានការិយាល័យមួយចំនួនចំណុះ ។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានចារកម្ម ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៥ ._**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា៦ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ១០ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- ឯកសារ-កាលប្បវត្តិ